ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**អាជ្ញាធរសវនកម្មជាតិ**

លេខ:០១៣/១៧....អសជ/សណជណ

ថ្ងៃ ពុធ ៤កើត ខែ មិគសិរ ឆ្នាំ រកា ព.ស. ២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ វិច្ឆិកា គ.ស ២០១៧

# សេចក្តីជូនដំណឹង

គណៈកម្មការរៀបចំការប្រឡង សូមជូនដំណឹងដល់បេក្ខជនដែលបានដាក់ពាក្យសុំសិទ្ធិប្រឡងប្រជែងចូលបម្រើការងារក្នុងក្របខ័ណ្ឌអាជ្ញាធរសវនកម្មជាតិសម្រាប់ឆ្នាំ២០១៧ ឱ្យបានជ្រាបថា គណៈកម្មការប្រឡងសូមធ្វើការកែប្រែដោយលុបចោលនូវវិញ្ញាសាផ្ទាល់មាត់និងអនុវត្តកុំព្យូទ័រ ហើយកាលបរិច្ឆេទ និងមណ្ឌលប្រឡងនៃវិញ្ញាសាសរសេរ មានដូចខាងក្រោម៖

I. **កាលបរិច្ឆេទប្រឡង៖ ថ្ងៃអាទិត្យ ទី ៣ ខែ ធ្នូ ឆ្នាំ២០១៧** តាមពេលវេលាដូចខាងក្រោម៖

- **ពេលព្រឹក**
  - ម៉ោង ០៦:២០ នាទី ៖ បេក្ខជនត្រូវមកដល់មណ្ឌលប្រឡង
  - ម៉ោង ០៧:១៥ នាទី - ០៧:៥០ នាទី ៖ អនុរក្សហៅឈ្មោះបេក្ខជនចូលបន្ទប់ប្រឡង ត្រួតពិនិត្យវត្តមាន ប្រកាសបទប្បញ្ញត្តិ និងចែកសន្លឹកកិច្ចការប្រឡង
  - ម៉ោង ០៨:០០ នាទី - ០៩:៣០ នាទី ៖ វិញ្ញាសាចំណេះដឹងទូទៅ
  - ម៉ោង ០៩:៤៥ នាទី - ១១:១៥ នាទី ៖ វិញ្ញាសាភាសាអង់គ្លេស
- **ពេលរសៀល**
  - ម៉ោង១២:៣៥ នាទី ៖ បេក្ខជនត្រូវមកដល់មណ្ឌលប្រឡង
  - ម៉ោង ០១:៣០ នាទី - ០២:០០ នាទី ៖ អនុរក្សហៅឈ្មោះបេក្ខជនចូលបន្ទប់ប្រឡង ត្រួតពិនិត្យវត្តមាន ប្រកាសបទប្បញ្ញត្តិ និងចែកសន្លឹកកិច្ចការប្រឡង
  - ម៉ោង ០២:១៥ នាទី - ០៥:១៥ នាទី ៖ វិញ្ញាសាជំនាញ

II. **មណ្ឌលប្រឡង៖ នៅវិទ្យាល័យ ជា ស៊ីម សន្ធរម៉ុក**

បញ្ជីរាយនាមបេក្ខជន ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដើម្បីចូលរួមប្រឡង មានបិតផ្សាយនៅទីស្តីការអាជ្ញាធរសវនកម្មជាតិ ឬគេហទំព័រអាជ្ញាធរសវនកម្មជាតិ (www.naa.gov.kh)។

អាស្រ័យហេតុនេះ សូមបេក្ខជនទាំងអស់ជ្រាបជាព័ត៌មាន និងសូមមកពិនិត្យប្លង់មណ្ឌលប្រឡង ឈ្មោះ លេខតុ និងលេខបន្ទប់ប្រឡងនៅទីស្តីការអាជ្ញាធរសវនកម្មជាតិ ឬវិទ្យាល័យ ជា ស៊ីម សន្ធរម៉ុក នៅថ្ងៃសៅរ៍ ទី២ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោង ៩:០០ នាទីព្រឹក។ បេក្ខជនដែលមានឈ្មោះចូលរួមប្រឡងត្រូវយកមកជាមួយនូវឯកសារ រួមមានសលាកបត្រឯកត្តជន និងបង្កាន់ដៃទទួលពាក្យ។

**ជ-គណៈកម្មការរៀបចំការប្រឡង**
**ប្រធាន**

**សោម គីមសួគ៌**


អគារលេខ ៥ ផ្លូវឌួងងៀប៣ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
# 5, St. Duong Ngeab 3, Sangkat Tekthla, Khan Sensok, Phnom Penh, CAMBODIA
Tel:(855-23) 885 900 (855-12) 737 622 Fax: (855-23) 885 900
E-mail: naakh@naa.gov.kh website: www.naa.gov.kh